**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

****************

**គណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**លេខ: ០៥៣ មស.នក**

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៩

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋលេខាធិការ**

**គ្រប់ក្រសួង-ស្ថាប័ន**

**កម្មវត្ថុ:** -ការណែនាំបន្ថែមនូវនីតិវិធីក្នុងការដំឡើងថ្នាក់ ការតាំងស៊ប់មន្ត្រីរាជការក្របខ័ណ្ឌថ្មី និងការ ដាក់មន្ត្រីរាជការ ស៊ីវិលឱ្យចូលនិវត្តន៍តាមគោលការណ៍។

**យោង:** -ព្រះរាជាក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានា។

-លិខិតលេខ ៦០០ ម.ស.ន.ក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីនីតិវិធី ក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងថ្នាក់ជូនមន្ត្រីរាជការស៊ីវិល។

ខ្ញុំមានកិត្តិយស សូមជម្រាបជូនឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់លេខាធិការ គ្រប់ក្រសួង-ស្ថាប័ន សូមជ្រាបថា បច្ចុប្បន្ន មន្ត្រីរាជការស៊ីវិល ត្រូវបានធ្វើសមាហរណកម្មទៅក្នុង ក្របខ័ណ្ឌ ថ្មីស្របតាមខ្លឹមសារ ព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែក នៃ ក្របខ័ណ្ឌនានារួចហើយនោះ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈសូមធ្វើ ការណែនាំបន្ថែម នូវនីតិវិធីមួយចំនួន ពាក់ព័ន្ធនឹងមន្ត្រីរាជការស៊ីវិល មានដូចខាងក្រោម:

**<u>១- ការស្នើសុំដំឡើងថ្នាក់មន្ត្រីរាជការស៊ីវិល</u>**

ក/ <u>ការដំឡើងថ្នាក់ប្រចាំឆ្នាំ</u>

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវផ្ញើឯកសារស្នើសុំដំឡើងថ្នាក់ប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល ឱ្យបានទាន់កាល កំណត់យ៉ាងយូរ (មុនដំណាច់ខែកុម្ភៈ សម្រាប់ឆ្នាំ២០០៩) មកឱ្យ រដ្ឋលេខាធិការដ្ឋាន មុខងារ

សាធារណៈដើម្បីរៀបចំធ្វើ សេចក្តីព្រាង ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ព្រមទាំង ផ្តល់ទិដ្ឋាការ ដំឡើងថ្នាក់ទៅតាមលក្ខន្តិកៈដោយឡែកឱ្យបាន សមស្រប និងតាមកាលបរិច្ឆេទកំណត់ គឺថ្ងៃទី ១៣ ខែ មេសា រៀងរាល់ឆ្នាំ។ ដើម្បីជាប្រយោជន៍ដល់មន្ត្រីរាជការស្នើក្រសួង-ស្ថាប័ននីមួយៗ យកចិត្តទុកដាក់ក្នុងការ រៀបចំសំណុំបែបបទនិងបញ្ជូនមកឱ្យបានទៀងទាត់និងទាន់ពេលវេលា។

ខ/ ការដំឡើងថ្នាក់តាមកម្រិតសញ្ញាប័ត្រ

ការស្នើសុំដំឡើងថ្នាក់មន្ត្រីរាជការតាមកម្រិតសញ្ញាប័ត្រ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ នឹងពិនិត្យ ផ្តល់ទិដ្ឋាការជូនលើសំណើសុំរបស់ក្រសួង-ស្ថាប័ន តែពីរលើកប៉ុណ្ណោះ គឺក្នុងខែឧសភា និងខែសីហា រៀងរាល់ឆ្នាំ។

**២- ការតាំងស៊ប់មន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌ តាមលក្ខន្តិកៈដោយឡែក**

កន្លងមក រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បានពិនិត្យឃើញក្រសួង-ស្ថាប័ន មួយចំនួនអនុវត្តពុំទាន់បាន ត្រឹមត្រូវទៅតាមខ្លឹមសារព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានានៅឡើយ ជាពិសេសនីតិវិធីនៃការតាំងស៊ប់មន្ត្រីរាជការក្របខ័ណ្ឌថ្មីទៅក្នុងក្របខ័ណ្ឌតាមលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានានៅឡើយ ជាពិសេសនីតិវិធីនៃការតាំង ស៊ប់មន្ត្រីរាជាការក្របខ័ណ្ឌថ្មីទៅក្នុងក្របខ័ណ្ឌតាមលក្ខន្តិកៈដោយឡែក ដែលក្របខ័ណ្ឌ "**ក**" ត្រូវតាំងស៊ប់ដោយព្រះរាជក្រឹត្យ និងក្របខ័ណ្ឌ " **ខ** " ត្រូវតាំងស៊ប់ដោយអនុក្រឹត្យ ដោយឡែកក្របខ័ណ្ឌ "**គ**" និង "**ឃ**" ត្រូវចេញដោយប្រកាស របស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈសម្រាប់តែក្របខ័ណ្ឌរដ្ឋបាលទូទៅ និងដោយប្រកាសរបស់ក្រសួង-ស្ថាប័ន គ្រប់គ្រង ក្របខ័ណ្ឌសម្រាប់ក្របខ័ណ្ឌដ៏ទៃទៀត ដោយមានទិដ្ឋាការ ពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។ បញ្ហានេះ ក្រសួង-ស្ថាប័នមួយចំនួន នៅអនុវត្តការ តាំងស៊ប់មន្ត្រីរាជការដោយប្រកាសរបស់ក្រសួង-ស្ថាប័នសាមីនៅឡើយ នាំឱ្យខុសពីនីតិវិធីនៃការតាំង ស៊ប់មន្ត្រី រាជការស៊ីវិល ដែលបានចែងក្នុងខ្លឹមសារព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈ ដោយឡែក។

ផ្អែកតាមវាក្យខ័ណ្ឌខាងលើនេះ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមជម្រាបជូនថា ចំពោះមន្ត្រី កម្មសិក្សាការីដែលបានបញ្ចប់ពេលវេលាកម្មសិក្សា និងទទួលលទ្ធផលបានជោគជ័យ ហើយមានការវាយតម្លៃត្រឹមត្រូវពី គណកម្មការរួចហើយ គ្រប់ក្រសួង-ស្ថាប័នសាមី ត្រូវបញ្ជូនសំណុំលិខិតស្នើ សុំតាំងស៊ប់មន្ត្រីរាជការទាំងនេះ ទៅក្នុងក្រប ខ័ណ្ឌតាមលក្ខន្តិកៈដោយឡែក មករដ្ឋលេខាធិការដ្ឋាន មុខងារ សាធារណៈ នៅខែបន្ទាប់ ដើម្បីរៀបចំបែបបទតាមនីតិវិធីស្តីពី ការតាំងស៊ប់មន្ត្រីរាជការស៊ីវិល ដែលមានចែង ក្នុងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក។

**៣- នីតិវិធីដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍**

ដើម្បីឱ្យសមស្របតាមខ្លឹមសារព្រះរាជក្រម ស្តីពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា និងសារាចរលេខ ០២ សរ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូល និវត្តន៍ គ្រប់ក្រសួង-ស្ថាប័នសាមី ត្រូវអនុវត្តនូវនីតិវិធីក្នុងការដាក់មន្ត្រីរាជការស៊ីវិលទាំងពីរភេទឱ្យចូលនិវត្តន៍ទៅតាម គោលការណ៍ ដែលមានចែង ក្នុងខ្លឹមសារព្រះរាជក្រឹត្រស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានា ឱ្យបានទាន់ពេលវេលា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីរដ្ឋលេខាធិ ការគ្រប់ក្រសួង-ស្ថាប័ន មេត្តាអនុវត្តតាមខ្លឹមសារខាងលើតាមការគួរ។

សូមឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន មេត្តា ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាប "
-គ្រប់សាលាខេត្ត-ក្រុង " ដើម្បីអនុវត្ត "

ពេជ្រ ប៊ុនធិន

-ឯកសារ-កាលប្បវត្តិ